ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# មតិសំណេះសំណាល
## លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ក្នុងពិធីបុណ្យសម្ពោធឆ្លងឧបដ្ឋានសាលា ពុទ្ធាភិសេក និងសមិទ្ធផលនានា
## នៅក្នុងវត្តមុនីរតនារាម (ហៅវត្តល្អក់)
## កំពង់ថ្ម ថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំថោះបញ្ចស័ក ព.ស.២៥៦៧
## ត្រូវនឹងថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៤

- សូមក្រាបថ្វាយបង្គំព្រះទេពសត្ថា សៀង សុខ ព្រះរាជាគណៈថ្នាក់ចត្វានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះសត្ថាបារមីព្រះមេគណខេត្តកំពង់ធំ ជាទីគោរពសក្ការៈ!
- សូមក្រាបថ្វាយបង្គំព្រះនិមលធម្មមុនី សោម ជាន ព្រះរាជាគណៈថ្នាក់កិត្តិយសនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះនិមលធម្មល័ក្ខណ៍ព្រះអនុគណស្រុកសន្ទុក ជាទីគោរពសក្ការៈ!
- សូមក្រាបថ្វាយបង្គំព្រះគ្រូអធិប្បញ្ញោ សុក ឌីម ព្រះគ្រូចៅអធិការវត្ត ព្រមទាំង ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!

**សូមគោរព៖**

- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអាជ្ញាធរដែនដី និងសហការី
- លោកតា លោកយាយ បងប្អូនពុទ្ធបរិស័ទទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំនិងសហការី មានកិត្តិយសនិងសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងពិធីបុណ្យឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានា នៅក្នុងវត្តមុនីរតនារាម ហៅ **វត្តល្អក់** ស្ថិតនៅភូមិល្អក់ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ នាឱកាសដ៏វិសេសវិសាលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមនាំមកនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ ឯកឧត្តមបណ្ឌិត **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាសមាជិករដ្ឋសភា នីតិកាលទី ៧ និងលោកជំទាវ **ខៀវ ស៊ីណា** ជូនលោកតា-លោកយាយ ពូមីង បងប្អូន និងក្មួយៗទាំងអស់ ក្នុងមនោសញ្ចេតនានឹករលឹក និងស្រលាញ់ដ៏ជ្រាលជ្រៅ ហើយខ្ញុំក៏សូមថ្លែងអំណរគុណជាអនេក ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងពិធីនាព្រឹកនេះ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**- ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ បងប្អូនពុទ្ធបរិស័ទទាំងអស់ ជាទីមេត្រី !**

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងសរសើរយ៉ាងក្រៃលែងចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងពុទ្ធបរិស័ទទាំងអស់ដែលបានរួមចំណែកផ្តល់វិភាគទានដល់ការកសាងសមិទ្ធផលទាំងនេះ ឱ្យចេញជារូបរាងឡើងតាមគន្លងព្រះពុទ្ធសាសនា។ សមិទ្ធផលថ្ងៃនេះ ឆ្លុះបញ្ចាំងអំពីការដឹកនាំ និងការចូលរួមចំណែកជាកុសលដ៏ធំធេងរបស់អាជ្ញាធរ ព្រះចៅអធិការវត្ត គណៈកម្មការអាចារ្យវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់។ សកម្មភាពទាំងនេះជាកុសលធំណាស់ **ដូចពុទ្ធភាសិតមួយបានពោលថា "សុខោ បុញ្ញស្ស ឧច្ចយោ" ៖ ការសន្សំបុណ្យជាហេតុនាំមកនូវសេចក្តីសុខ។**

ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមចូលរួមសប្បាយរីករាយផងដែរ ជាមួយបងប្អូនប្រជាពលរដ្ឋដែលបានចូលរួមយ៉ាងច្រើនកុះករក្នុងពិធីនេះ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីជំនឿយ៉ាងខ្ជាប់ខ្ជួន និងការគោរពប្រណិប័តន៍ដ៏ប្រពៃចំពោះព្រះពុទ្ធសាសនា ហើយបានបង្ហាញនូវការគាំទ្ររបស់បងប្អូនចំពោះរាជរដ្ឋាភិបាល ក្រោមដំបូលសន្តិភាពដែលជាមរតកដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងការបន្តថែរក្សាដំបូលសន្តិភាពដែលដឹកនាំដោយ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជានិច្ចកាលតែងតែគិតគូរ យកចិត្តទុកដាក់ និងខិតខំស្វែងរកគ្រប់មធ្យោបាយ ដើម្បីដោះស្រាយរាល់ការលំបាកក្នុងជីវភាពរបស់ប្រជាជនយើងជាពិសេសនៅតំបន់ជនបទ សំដៅសម្រេចកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើងនៅទូទាំងប្រទេស ព្រមទាំងបានខិតខំកសាងសមិទ្ធផលក្នុងវិស័យអាណាចក្រ និងពុទ្ធចក្រដូចជា៖

- សាលារៀន វិទ្យាល័យ
- មន្ទីរពេទ្យ
- វត្តអារាម ព្រះវិហារ
- ផ្លូវគមនាគមន៍
- ទឹកស្អាត
- អគ្គិសនី និង
- ប្រព័ន្ធធារាសាស្ត្រ ជាដើម។

សមិទ្ធផលដែលសម្រេចបានទាំងអស់នេះ កើតឡើងដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាបានសន្តិភាពពេញលេញ និងស្ថិរភាពនយោបាយ។ ពុទ្ធចក្រ និងអាណាចក្រត្រូវដើរទន្ទឹមគ្នា ពឹងគ្នាទៅវិញទៅមក និងជួយទំនុកបម្រុងគ្នាទៅវិញទៅមក។ ពុទ្ធចក្រជួយផ្នែកស្មារតីផ្នែកខាងទស្សនវិជ្ជា ដោយសារមានពុទ្ធចក្រទើបអាណាចក្រអាចរុងរឿងបាន។ ជាមួយគ្នានេះ ពុទ្ធចក្រក៏ពឹងផ្អែកនិងផ្ញើលើរដ្ឋអំណាចផងដែរ ក្នុងនោះដោយសារមានសុខសន្តិភាពស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនេះហើយ ទើបជំនឿសាសនាមាននិរន្តរភាពនិងភាពរុងរឿង។ ជាក់ស្តែង ក្នុងរបប ប៉ុល ពត ខ្មែរក្រហម បានបំផ្លាញចោលស្ទើរទាំងស្រុងនូវរចនាសម្ព័ន្ធក្នុងវិស័យ

អាណាចក្រ និងពុទ្ធចក្រ ទាំងអគារ ទីផ្សារ រោងចក្រ សាលារៀន វត្តអារាម សាលាបាលី និងព្រះវិហារជាដើម។ ខ្មែរក្រហម បានប្រែក្លាយសង្គមកម្ពុជាទៅជាសង្គមទាសភាពបុព្វកាល ពុទ្ធចក្រធ្លាក់ដល់ចំណុចសូន្យ បំបិទជំនឿសាសនា រីឯផ្នែកអាណាចក្រក៏បានធ្លាក់ដុនដាបផងដែរ។ *(ដូចលោកអភិបាលស្រុកបានរៀបរាប់អំពីប្រវត្តិសង្ខេបរបស់វត្តល្អក់ចាប់តាំងពីការកកើតវត្តតាំងពី ៦៨ឆ្នាំមុន (១៩៥៦) ជាពិសេសប្រវត្តិដ៏ជូរចត់នៅឆ្នាំ១៩៧៥-១៩៧៩ វត្តល្អក់ដែលជាទីសក្ការៈបូជារបស់ប្រជាពលរដ្ឋត្រូវបានប្រែក្លាយទៅជាកន្លែងដាក់គ្រាប់រំសេវ និងសម្ភារៈផ្សេងៗទៅវិញ។)*

ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ យើងបានរៀបចំឱ្យមានលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងស្ថិរភាពនយោបាយ។ ប្រទេសកម្ពុជាយើងទទួលបានសុខសន្តិភាពពេញលេញ ក្នុងនោះរដ្ឋាភិបាល មានលទ្ធភាពគ្រប់គ្រាន់ក្នុងការកសាងប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ និងបានប្រែក្លាយទីវត្តអារាមនានា មកជាទីសក្ការៈបូជាសម្រាប់លោកតា លោកយាយ ពូមីង និងបងប្អូនប្រជាពលរដ្ឋយើងវិញ ដោយមានសមិទ្ធផលលេចឡើងជារូបរាងថ្មីៗបន្ថែមទៀតផងដែរ។ រាជរដ្ឋាភិបាលថ្មីក្រោមការដឹកនាំរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តលើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ដូចបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងចារឹកជាបាវចនារបស់ប្រទេសជាតិ គឺ "**ជាតិ សាសនា ព្រះមហាក្សត្រ**" នឹងបន្តខិតខំធ្វើឱ្យទីវត្តអារាមក្លាយជាមជ្ឈមណ្ឌលនៃជីវភាពខាងស្មារតី ដែលចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមជាតិ ខាងផ្នែកវប្បធម៌ អប់រំសុខាភិបាល សង្គមកិច្ច និងសីលធម៌សង្គម។

- **ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ បងប្អូនពុទ្ធបរិស័ទទាំងអស់ជាទីមេត្រី !**

ថ្ងៃនេះ យើងរៀបចំពិធីបុណ្យឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលផ្សេងៗនៅក្នុងវត្តមុនីរតនារាម (វត្តល្អក់) ដែលសមិទ្ធផលទាំងនេះ មិនត្រឹមតែឆ្លុះបញ្ចាំងពីការរីកចម្រើនក្នុងវិស័យពុទ្ធចក្រប៉ុណ្ណោះទេ ប៉ុន្តែជាសមិទ្ធផលជារូបវន្តក្នុងវិស័យអាណាចក្រយើងផងដែរ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពីអត្ថន័យនៃឧបដ្ឋានសាលា។ ឧបដ្ឋានសាលា ជាភាសាសាមញ្ញហៅថា សាលាឆាន់គឺជាទីដែលឧបាសក ឧបាសិកា ពុទ្ធបរិស័ទទាំងអស់ ប្រគេនចង្ហាន់ដល់ព្រះសង្ឃ សមាទាននិច្ចសីល និងឧបោសថសីល ព្រមទាំងជាទីដែលបងប្អូន ពូមីង លោកតា លោកយាយ ពុទ្ធបរិស័ទជួបជុំគ្នា។ ឧបដ្ឋានសាលាមកអំពីពាក្យថា ឧបដ្ឋាន+សាលា ដោយឧបដ្ឋានមានន័យថា ការបម្រើ ការទំនុកបម្រុង ឬការផ្គត់ផ្គង់ ឧទាហរណ៍ បុត្រធីតាត្រូវឧបដ្ឋានមាតាបិតា។ រីឯពាក្យសាលាមានន័យថា ជាផ្ទះ ជាមន្ទីរ ជារោង។ ដូច្នេះ ឧបដ្ឋានសាលា មានន័យថា ជាទីមន្ទីរសម្រាប់បម្រើដល់ព្រះពុទ្ធសាសនា សម្រាប់ទំនុកបម្រុងដល់ព្រះសង្ឃ សម្រាប់ប្រជុំគ្នាធ្វើទាន និងសម្រាប់ជួយគ្នាទៅវិញទៅមក។

ទន្ទឹមនេះ យើងទាំងអស់គ្នានៅទីនេះ សាធុសប្បុរសជន ញាតិមិត្តជិតឆ្ងាយ បានរួមគ្នាធ្វើបុណ្យឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលផ្សេងៗ ដើម្បីទុកជាប្រយោជន៍រួមរបស់ លោកតា

លោកយាយ ពូមីង បងប្អូនទាំងអស់គ្នា ហើយយើងអាចធ្វើបុណ្យរួមគ្នានៅក្នុងទីនេះទៀតផង។ នេះបង្ហាញពីស្មារតីសាមគ្គីភាព និងភាតរភាពរវាងលោកតា លោកយាយ ពូមីង បងប្អូន ពុទ្ធបរិស័ទ ចំណុះជើងវត្តល្អក់ទាំងអស់។ ជាមួយគ្នានេះ អានិសង្សដែលបានមកពីបុណ្យឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលផ្សេងៗ ខ្ញុំសូមចែកជូន លោកតា លោកយាយ ពូមីង បងប្អូនឱ្យបានស្មើៗគ្នា និង សូមឱ្យលោកតា លោកយាយ ពូមីង បងប្អូនទាំងអស់គ្នា អនុមោទនា ទទួលយកកុសលផលបុណ្យ នេះឱ្យបានស្មើៗគ្នា។

***សុភាសិតបាលីថា "សាមគ្គី សាមគ្គានំ តបោ សុខោ" មានន័យថា ការសាមគ្គីគ្នា នាំមកនូវសេចក្ដីសុខសប្បាយ ។***

អ្វីៗដែលយើងទទួលបានសព្វថ្ងៃ កើតចេញពីការខិតខំប្រឹងប្រែងយូរអង្វែង។ ហេតុនេះ រាជរដ្ឋាភិបាល ដែលកើតចេញពីគណបក្សប្រជាជនកម្ពុជា តែងតែខិតខំប្រឹងប្រែងថែរក្សាការពារ សមិទ្ធផលទាំងនេះ និងបន្តពង្រឹងស្ថិរភាពនយោបាយ សន្តិភាព សន្តិសុខ និងសុវត្ថិភាព ព្រមទាំង លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជារួម គណបក្សប្រជាជនកម្ពុជាយើង តែងតែនៅជិត ជាមួយបងប្អូនប្រជាពលរដ្ឋ ជួយដោះស្រាយទុក្ខលំបាកជូនប្រជាពលរដ្ឋ ជាពិសេសបាននាំមកនូវ សន្តិភាព និងការអភិវឌ្ឍ ។ ដូច្នេះ ដើម្បីបន្តនិរន្តរភាព និងការអភិវឌ្ឍបន្ថែមទៀត សូមលោកតា លោកយាយ ពូមីង បងប្អូនទាំងអស់ បន្តគាំទ្រ ក៏ដូចជាចូលរួមជាមួយរាជរដ្ឋាភិបាលបន្តទៀត។

*១/- សូមអំពូមីងបងប្អូនបន្តចូលរួមអនុវត្តនិងគាំទ្រគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ដោយសហការជាមួយអាជ្ញាធរគ្រប់ជាន់ថ្នាក់ កងកម្លាំងមានសមត្ថកិច្ច និងកម្លាំងប្រជាការពារទប់ស្កាត់ បទល្មើសផ្សេងៗ រួមមានបញ្ហាគ្រឿងញៀន និងល្បែងស៊ីសងជាដើម។ លើសពីនេះ សូមចូលរួម ថែរក្សាអនាម័យសហគមន៍យើងឱ្យមានបរិស្ថានល្អ ដូចជា នៅក្នុងទីធ្លាវត្តអារាមនេះ ជាដើម។*

*២/- ផ្លូវដើររបស់ក្មួយៗនៅវែងឆ្ងាយ សូមក្មួយៗព្យាយាមសិក្សារៀនសូត្រ ជៀសឱ្យឆ្ងាយ ពីក្រុមក្មេងទំនើង និងគ្រឿងញៀន ព្រមទាំងគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា ដើម្បីសុវត្ថិភាព ផ្ទាល់ខ្លួន និងសហគមន៍យើង ព្រមទាំងចូលរួមថែរក្សាអនាម័យទីធ្លាសាលា ដើម្បីទទួលបានបរិស្ថាន សិក្សាល្អ។*

*៣/- ធនាគារជាតិនៃកម្ពុជាក៏បាននិងបន្តលើកកម្ពស់ការអប់រំដល់ក្មួយៗទាំងអស់ ដូចជា ការឧបត្ថម្ភវត្ថុបំប៉នបន្ថែមជារៀងរាល់ឆ្នាំ សម្រាប់សិស្សប្រឡងសញ្ញាបត្រទុតិយភូមិ (ថ្នាក់ទី១២) ការបណ្ដាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សិស្សានុសិស្សក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅពីថ្នាក់ទី១ ដល់ទី១២ និង យុទ្ធនាការអប់រំខ្លីៗ ដូចជា ការបោះពុម្ពសៀវភៅ "តោះ! និយាយពីលុយ" ដែល លើកកម្ពស់ការយល់ដឹងលើការគ្រប់គ្រងប្រាក់កាក់ប្រកបដោយភាពវៃឆ្លាត ដូចជាការរៀបចំ ផែនការចំណូលចំណាយការសន្សំ និងការប្រើប្រាស់លុយកម្ចីឱ្យត្រឹមត្រូវ។*

*៤/- ខ្ញុំកំពុងរៀបចំវចនានុក្រមនៃការប្រើពាក្យពេជ្យជាមួយស្ដេច (រាជសព្ទ) និងពាក្យពេចន៍ សម្រាប់ប្រាស្រ័យទាក់ទងជាមួយព្រះសង្ឃ (សង្ឃសព្ទ) ឱ្យបានត្រឹមត្រូវ។*

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ ចំពោះការខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការកសាងសមិទ្ធផល ជាច្រើនទាំងក្នុងវិស័យពុទ្ធចក្រនិងអាណាចក្រ នៅទូទាំងស្រុកសន្ទុក ក៏ដូចជាខេត្តកំពង់ធំទាំងមូល។ ខ្ញុំសូមឧទ្ទិសសមិទ្ធផលទាំងនេះទុកជាសម្បត្តិក្នុងព្រះពុទ្ធសាសនា និងសូមបងប្អូនប្រជាពលរដ្ឋយើង ទាំងអស់គ្នា ខិតខំថែរក្សាការពារសមិទ្ធផលទាំងអស់ ក្នុងវត្តល្អក់យើងឱ្យបានគង់វង្ស និងសម្រាប់ ទុកជាទីសក្ការៈគោរពបូជារបស់ពុទ្ធសាសនិកជនជិតឆ្ងាយទាំងអស់។

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរចំពោះព្រះតេជគុណ ព្រះចៅអធិការវត្ត ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរ ឯកឧត្តម លោកជំទាវ ឧបាសក ឧបាសិកា លោកតា លោកយាយ បងប្អូនប្រជាពលរដ្ឋ ទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជាពិសេស សូមប្រគេន និជូនពរជ័យសិរីសួស្តី និងវិបុលសុខ គ្រប់ព្រះកាយ និងគ្រប់ៗគ្នា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧។

សូមឧទ្ទិសជូនមគ្គផលឱ្យបានស្មើៗគ្នា។

**សូមអរព្រះគុណ និងអរគុណ!**